អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## ប្រទេសម៉ាឡេស៊ីផ្តល់វិភាគទាន ៥0 000 ដុល្លារសហរដ្ឋអាម៉េរិកដល់ អ.វ.ត.ក

រដ្ឋាភិបាលម៉ាឡេស៊ី បានផ្តល់វិភាគទានជាទឹកប្រាក់ចំនួន ៥0 000 ដុល្លារសហរដ្ឋអាម៉េរិកដល់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ម៉ាឡេស៊ីជាប្រទេសម្ចាស់ជំនួយថ្មីមួយទៀតរបស់ អ.វ.ត.ក ហើយ ការផ្តល់វិភាគទាននេះធ្វើឡើងដើម្បីឆ្លើយតបនឹងការអំពាវនាវរបស់ឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា។ សហគមន៍អន្តរជាតិត្រូវបានស្នើសុំឲ្យជួយផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុជាបន្ទាន់ដល់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានមានប្រសាសន៍ថា៖“ យើងខ្ញុំមានក្តីសោមនស្សរីករាយ ស្វាគមន៍ប្រទេសម៉ាឡេស៊ី ក្នុងនាមជាប្រទេសម្ចាស់ជំនួយថ្មីរបស់ អ.វ.ត.ក ហើយយើងខ្ញុំសូមសម្តែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះរដ្ឋាភិបាលម៉ាឡេស៊ីដែលបានផ្តល់វិភាគទាននេះ”។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ 0២៣
សារអេឡិកត្រូនិក: olsenl@un.org